**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ**១០០០**អយក.**ប្រក

# ប្រកាស
## ស្តីពី
## ការបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន "សាលាគ្លូលីនអន្តរជាតិភ្នំពេញ"

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ខែធ្នូឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩២ ស្តីពីការបើកសាលារៀនចំណេះទូទៅឯកជន
- បានពិនិត្យលិខិតស្នើសុំរបស់លោកស្រី **គីម ឆាងស៊ីក** ជានាយិកាគ្រឹះស្ថានសិក្សា ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

## សម្រេច

**ប្រការ ១**.-

ត្រូវបានអនុញ្ញាតឱ្យបើកគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន" **សាលាគ្លូលីនអន្តរជាតិភ្នំពេញ** " ចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ១៣១ ផ្លូវលេខ១៩២៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០១៧-២០១៨ នេះតទៅ។

**ប្រការ ២**.-

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាគ្លូលីនអន្តរជាតិភ្នំពេញ** ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងត្រូវអនុវត្តតាមកម្មវិធីសិក្សាអន្តរជាតិ។

**ប្រការ ៣**.-

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាគ្លូលីនអន្តរជាតិភ្នំពេញ** ត្រូវតម្កល់ប្រាក់ធានាអនុវត្តកិច្ចសន្យាតាមចំនួនកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងរតនាគារជាតិ សម្រាប់ធានាផលប្រយោជន៍តាមផ្លូវច្បាប់ចំពោះបុគ្គលិកនិងអ្នកសិក្សាក្នុងគ្រឹះស្ថានសិក្សា។

**ប្រការ ៤.-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាគ្លូលីខអន្តរជាតិភ្នំពេញ** ត្រូវមានកម្មវិធីសិក្សាភាសាបរទេសណាមួយជាមុខវិជ្ជាគោល នៃកម្មវិធីសិក្សារបស់ខ្លួន។

**ប្រការ ៥.-**

លោកស្រី **គីម ឆាងស៊ុក** ជានាយិកាគ្រឹះស្ថានសិក្សាត្រូវដឹកនាំ និងគ្រប់គ្រងសាលារៀនទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវ៖

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យ
- ជ្រើសរើសសិស្សឱ្យចូលរៀនដោយមិនមានការរើសអើង
- ធានាដំណើរការបង្រៀន និងរៀនឱ្យប្រកបដោយគុណភាព និងប្រសិទ្ធភាព
- គោរព និងអនុវត្តសារាចរ សេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ធានាសណ្ដាប់ធ្នាប់សង្គម និងធានាសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តចំពោះសិស្សគ្រប់រូប
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាផ្នែករដ្ឋបាល និងបច្ចេកទេសជូនមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**ប្រការ ៦.-**

ក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ហើយមានសិទ្ធិបិទ ប្រសិនបើគ្រឹះស្ថានសិក្សានេះអនុវត្តខុសពីកិច្ចសន្យាដែលបានចុះជាមួយក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ៧.-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាគ្លូលីខអន្តរជាតិភ្នំពេញ** ត្រូវបានកំណត់ឱ្យមានសុពលភាពរយៈពេល ៥ឆ្នាំ ដោយគិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៣ ពេលផុតកំណត់គ្រឹះស្ថានសិក្សាត្រូវសុំបន្តសុពលភាពសារជាថ្មី ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គាធិការដ្ឋាន នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ អង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ និងគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាគ្លូលីខអន្តរជាតិភ្នំពេញ** និងសាមីជនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០១៧

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានីភ្នំពេញ

*"ដើម្បីជូនជ្រាបជាព័ត៌មាន"*

- ដូចប្រការ៨

*"ដើម្បីអនុវត្ត"*

- កាលប្បវត្តិ- ឯកសារច្រកចេញចូលតែមួយក្រសួងអប់រំ យុវជន និងកីឡា

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៨៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh